- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៩៣ សសរ**

# សេចក្តីសម្រេច
# ស្តីពី
# ការជ្រើសរើសពលទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**ប្រការ១ :** អនុញ្ញាតឲ្យក្រសួងការពារជាតិ ជ្រើសរើសពលទាហានថ្មី ចំនួន ៤០០ (បួនរយ)នាក់ ដើម្បីបំពេញក្របខ័ណ្ឌឲ្យបញ្ជាការដ្ឋានកងទ័ពជើងទឹក អគ្គបញ្ជាការដ្ឋាន។

**ប្រការ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃសុក្រ ១កើត ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
  អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១០៣០ ...សហវ.ក.ហក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តគំរូប្រកាសស្តីពីការបង្កើតអង្គភាពគ្រប់គ្រងគម្រោង/កម្មវិធី, គណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្ម, គណៈកម្មការវាយតម្លៃឯកសារដេញថ្លៃទំនិញ និងសំណង់, និងគណៈកម្មការវាយតម្លៃឯកសារជ្រើសរើសទីប្រឹក្សា សម្រាប់គម្រោង/កម្មវិធីក្រោមក្របខណ្ឌហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍, ពីការឱ្យខ្ចីផ្ទាល់ពីរដ្ឋ, និងពីមូលបត្ររដ្ឋ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩២ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការកែសម្រួលមាត្រា ១ នៃអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១._**

ត្រូវបានដាក់ឱ្យអនុវត្តគំរូប្រកាសចំនួន ២ គឺ÷ ១) គំរូប្រកាសស្តីពីការបង្កើតអង្គភាពគ្រប់គ្រងគម្រោង/កម្មវិធីក្រោមក្របខណ្ឌហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍, ពីការឱ្យខ្ចីផ្ទាល់ពីរដ្ឋ និងពីមូលបត្ររដ្ឋ; និង ២) គំរូប្រកាសស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្ម, គណៈកម្មការវាយតម្លៃឯកសារដេញថ្លៃទំនិញ និងសំណង់, និងគណៈកម្មការវាយតម្លៃឯកសារជ្រើសរើសទីប្រឹក្សា សម្រាប់គម្រោង/កម្មវិធីក្រោមក្របខណ្ឌហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍, ពីការឱ្យខ្ចីផ្ទាល់ពីរដ្ឋ និងពីមូលបត្ររដ្ឋ ដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ២._**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះក្រសួង ស្ថាប័នសាធារណៈ, មន្ទីរជំនាញរាជធានី ខេត្ត, រដ្ឋបាលថ្នាក់ក្រោមជាតិ, សហគ្រាសសាធារណៈ, គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែលដែលអនុវត្តគម្រោង/កម្មវិធីក្រោមក្របខណ្ឌហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍, ពីការឱ្យខ្ចីផ្ទាល់ពីរដ្ឋ, និងពីមូលបត្ររដ្ឋ។

**ប្រការ៣._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ នាយកវិទ្យាស្ថាន និងគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃប្រកាសលេខ ១៣៣០ [illegible] ចុះថ្ងៃទី២៤ ខែ...[illegible]........ឆ្នាំ២០២២

ស្ដីពី

ការដាក់ឱ្យអនុវត្តគំរូប្រកាសស្ដីពីការបង្កើតអង្គភាពគ្រប់គ្រងគម្រោង/កម្មវិធី, គណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្ម, គណៈកម្មការវាយតម្លៃឯកសារដេញថ្លៃទំនិញ និងសំណង់, និងគណៈកម្មការវាយតម្លៃឯកសារជ្រើសរើសទីប្រឹក្សា សម្រាប់គម្រោង/កម្មវិធី ក្រោមក្របខណ្ឌហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍, ពីការខ្ចីផ្ទាល់ពីរដ្ឋ, និងពីមូលបត្ររដ្ឋ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*(សញ្ញាក្រសួង ស្ថាប័ន)*
***ក្រសួង ស្ថាប័ន*** *÷ [បញ្ចូលឈ្មោះក្រសួង ស្ថាប័ន...]*
***លេខ*** *÷ [...]*

**ប្រកាស**
**ស្តីពី**
**ការបង្កើតអង្គភាពគ្រប់គ្រងគម្រោង/កម្មវិធី** [ *បញ្ចូលឈ្មោះគម្រោង/កម្មវិធី...*]
**ក្រោមក្របខណ្ឌហិរញ្ញប្បទានពី** [ *បញ្ចូលឈ្មោះស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍.../ការឱ្យខ្ចីផ្ទាល់ពីរដ្ឋ.../មូលបត្ររដ្ឋ...*]

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង** [ *បញ្ចូលឈ្មោះក្រសួង...*] ឬ
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង** [ *បញ្ចូលឈ្មោះក្រសួង...*] ឬ
**រដ្ឋមន្ត្រីក្រសួង** [ *បញ្ចូលឈ្មោះក្រសួង...*] ឬ
**ប្រធានស្ថាប័ន** [ *បញ្ចូលឈ្មោះស្ថាប័ន...*]

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ *[បញ្ចូលអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន...]*
- បានឃើញអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- បានឃើញអនុក្រឹត្យលេខ ១៩២ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការកែសម្រួលមាត្រា ១ នៃអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- បានឃើញប្រកាសលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ.... ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋាន... *(ក្នុងករណីបើមាន)*
- យោងតាមតម្រូវការចាំបាច់របស់ *[បញ្ចូលឈ្មោះក្រសួង ស្ថាប័ន...]*

សម្រេច

**ប្រការ១.**

ត្រូវបានបង្កើតអង្គភាពគ្រប់គ្រងគម្រោង/កម្មវិធី [*បញ្ចូលឈ្មោះគម្រោង/កម្មវិធី...*] ក្រោមក្របខណ្ឌហិរញ្ញប្បទានពី [*បញ្ចូលឈ្មោះស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍.../ការឱ្យខ្ចីផ្ទាល់ពីរដ្ឋ.../មូលបត្ររដ្ឋ...*] ដែលមានសមាសភាព ដូចខាងក្រោម÷

**ក. អង្គភាពគ្រប់គ្រងគម្រោង/កម្មវិធី**

| | |
|---|---|
| ១. [*បញ្ចូលឈ្មោះ ...*] | នាយកគម្រោង/កម្មវិធី |
| ២. [*បញ្ចូលឈ្មោះ ...*] | ប្រធានគ្រប់គ្រងគម្រោង/កម្មវិធី |
| ៣. [*បញ្ចូលឈ្មោះ ...*] | មន្ត្រីទទួលបន្ទុករដ្ឋបាល |
| ៤. [*បញ្ចូលឈ្មោះ ...*] | មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ |
| ៥. [*បញ្ចូលឈ្មោះ ...*] | មន្ត្រីទទួលបន្ទុកលទ្ធកម្ម |
| ៦. [*បញ្ចូលឈ្មោះ ...*] | មន្ត្រីទទួលបន្ទុកបច្ចេកទេស |
| ៧. [*បញ្ចូលឈ្មោះ ...*] | មន្ត្រីទទួលបន្ទុកត្រួតពិនិត្យ និងវាយតម្លៃ |
| ៨. [*បញ្ចូលឈ្មោះ ...*] | [*បញ្ចូលតួនាទីពាក់ព័ន្ធផ្សេងទៀត ប្រសិនបើមាន ...*]។ |

**ខ. អង្គភាពអនុវត្តគម្រោង/កម្មវិធី** [*ប្រសិនបើមាន*]

| | |
|---|---|
| ១. [*បញ្ចូលឈ្មោះ ...*] | ប្រធានអនុវត្តគម្រោង/កម្មវិធី |
| ២. [*បញ្ចូលឈ្មោះ ...*] | មន្ត្រីទទួលបន្ទុកបច្ចេកទេស |
| ៣. [*បញ្ចូលឈ្មោះ ...*] | [*បញ្ចូលតួនាទីពាក់ព័ន្ធផ្សេងទៀត ប្រសិនបើមាន ...*]។ |

**ប្រការ២.**

អង្គភាពគ្រប់គ្រងគម្រោង/កម្មវិធី មានភារកិច្ច និងការទទួលខុសត្រូវក្នុងការគ្រប់គ្រង និងអនុវត្តគម្រោង/កម្មវិធី ដែលក្នុងនោះមានជាអាទិ៍÷

- គ្រប់គ្រង តាមដាន និងសម្របសម្រួលរាល់ការអនុវត្តការងារពាក់ព័ន្ធនឹងគម្រោង/កម្មវិធី រួមទាំងបំពេញភារកិច្ចប្រចាំថ្ងៃពាក់ព័ន្ធនឹងការងាររដ្ឋបាលគម្រោង/កម្មវិធី
- គ្រប់គ្រង និងចាត់ចែងធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងសម្ភារផ្សេងៗ ដែលបម្រើដល់ការអនុវត្តគម្រោង/កម្មវិធី
- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់គម្រោង/កម្មវិធី ដើម្បីស្នើសុំការអនុម័តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង/ឬពីដៃគូអភិវឌ្ឍន៍ ឱ្យបានទាន់ពេលវេលាកំណត់ ព្រមទាំងតាមដានលទ្ធផលនៃការអនុវត្តថវិកា
- ដឹកនាំ និងអនុវត្តរាល់កិច្ចលទ្ធកម្មសម្រាប់ទំនិញ សំណង់ និងសេវាទីប្រឹក្សា ព្រមទាំងគ្រប់គ្រង និងតាមដានការអនុវត្តកិច្ចសន្យា
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគម្រោង/កម្មវិធី របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ផ្សេងទៀត, និងផ្ញើជូនក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ តាមកាលបរិច្ឆេទដែលបានកំណត់
- សម្របសម្រួលការចុះធ្វើសវនកម្មលើគម្រោង/កម្មវិធី និងចាត់វិធានការកែតម្រូវលើចំណុចខ្វះខាតដែលរកឃើញដោយសវនករ
- ធានាសម្រេចបាននូវលទ្ធផលរបស់គម្រោង/កម្មវិធីទៅតាមពេលវេលា និងធនធានដែលបានកំណត់
- ធានាអនុលោមភាពនៃការអនុវត្តគម្រោង/កម្មវិធី ស្របតាមគោលការណ៍ណែនាំ បែបបទ និងនីតិវិធីដែលបានកំណត់ និងឯកភាពជាមួយដៃគូអភិវឌ្ឍន៍ និង/ឬរាជរដ្ឋាភិបាល

- អនុវត្តភារកិច្ចផ្សេងទៀត តាមការកំណត់ក្នុងនីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំគម្រោង និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ (Standard Operating Procedures for Implementing All Externally Financed Projects/Programs) និងឯកសារគ្រប់គ្រងគម្រោង/កម្មវិធីពាក់ព័ន្ធផ្សេងទៀត ដើម្បីឱ្យការអនុវត្តគម្រោង/កម្មវិធីប្រព្រឹត្តទៅដោយរលូន និងបញ្ចប់ទាន់ពេលវេលា។

**ប្រការ៣_**

អង្គភាពគ្រប់គ្រងគម្រោង/កម្មវិធី ត្រូវដឹកនាំដោយនាយកគម្រោង/កម្មវិធី ដែលបំពេញតួនាទីគ្រប់គ្រង និងត្រួតពិនិត្យលើការអនុវត្តគម្រោង/កម្មវិធីជារួម និងប្រធានគ្រប់គ្រងគម្រោង/កម្មវិធី ដែលមានតួនាទីអនុវត្តសកម្មភាពការងារប្រចាំថ្ងៃរបស់គម្រោង/កម្មវិធី÷

ក. នាយកគម្រោង/កម្មវិធី មានភារកិច្ច និងការទទួលខុសត្រូវជាសារវន្ត ដែលក្នុងនោះមានជាអាទិ៍÷

- ចូលរួមជាសមាសភាពហត្ថលេខីក្នុងការបើកគណនីធនាគាររបស់គម្រោង/កម្មវិធី
- ដឹកនាំរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំមុនពេលដាក់សំណើរទៅរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដឹកនាំការប្រជុំប្រចាំត្រីមាស ឬតាមការចាំបាច់ ដើម្បីពិនិត្យវឌ្ឍនភាពនៃការអនុវត្តចំណាយថវិកា និងរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ពីវឌ្ឍនភាពរបស់គម្រោង/កម្មវិធី
- ពិនិត្យ និងអនុម័តរាល់ការចំណាយ និងដកសាច់ប្រាក់ ដែលប្រើមូលប្បទានប័ត្រ ឬតាមរយៈការផ្ទេររវាងធនាគារនិងធនាគារ ដែលមានទឹកប្រាក់ចាប់ពី...ដុល្លារអាមេរិក រហូតដល់...ដុល្លារអាមេរិក [*បញ្ចូលចំនួនទឹកប្រាក់ដែលត្រូវបានប្រគល់សិទ្ធិពីក្រសួង ស្ថាប័ន...*]
- ពិនិត្យ និងអនុម័តលើរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស ឬឆមាស និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់សវនកម្ម
- មានសិទ្ធិចុះហត្ថលេខាលើកិច្ចសន្យាលទ្ធកម្មដែលមានទឹកប្រាក់ចាប់ពី...ដុល្លារអាមេរិក រហូតដល់...ដុល្លារអាមេរិក [*បញ្ចូលចំនួនទឹកប្រាក់ដែលត្រូវបានប្រគល់សិទ្ធិពីក្រសួង ស្ថាប័ន ...*]
- អនុវត្តភារកិច្ចផ្សេងទៀត តាមការកំណត់ក្នុងនីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំគម្រោង និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងឯកសារគ្រប់គ្រងគម្រោង/កម្មវិធីពាក់ព័ន្ធផ្សេងទៀត។

ខ. ប្រធានគ្រប់គ្រងគម្រោង/កម្មវិធី មានភារកិច្ច និងការទទួលខុសត្រូវជាសារវន្ត ដែលក្នុងនោះមានជាអាទិ៍÷

- សម្របសម្រួលការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំមុនពេលដាក់ជូននាយកគម្រោង/កម្មវិធីពិនិត្យ
- ពិនិត្យរបាយការណ៍សវនកម្ម និងផ្តល់ការឆ្លើយតបចំពោះអនុសាសន៍របស់សវនករ
- ពិនិត្យ និងអនុម័តរាល់ការចំណាយ និងដកសាច់ប្រាក់ ដែលប្រើមូលប្បទានប័ត្រ ឬតាមរយៈការផ្ទេររវាងធនាគារនិងធនាគារ ដែលមានទឹកប្រាក់ក្រោម...ដុល្លារអាមេរិក [*បញ្ចូលចំនួនទឹកប្រាក់ដែលត្រូវបានប្រគល់សិទ្ធិពីក្រសួង ស្ថាប័ន ...*]
- ពិនិត្យ និងអនុម័តរាល់ការចំណាយជាសាច់ប្រាក់ដែលដកចេញពីបេឡារបស់គម្រោង/កម្មវិធីត្រឹមចំនួនអប្បបរមា ...ដុល្លារអាមេរិក [*បញ្ចូលចំនួនទឹកប្រាក់ដែលត្រូវបានប្រគល់សិទ្ធិពីក្រសួង ស្ថាប័ន...*]
- ពិនិត្យ និងអនុម័តរាល់ការកែតម្រូវចំណូល ចំណាយផ្សេងៗបើចាំបាច់ ដោយមិនគិតពីទំហំទឹកប្រាក់ និងអនុម័តរាល់ការជម្រះបញ្ជីបុរេប្រទានផ្សេងៗ។ល។
- ពិនិត្យ និងអនុម័តរាល់ចំណូលពីគ្រប់ប្រភពហិរញ្ញប្បទាន សម្រាប់ការអនុវត្តគម្រោង/កម្មវិធី ដោយមិនគិតពីទំហំទឹកប្រាក់

- មានសិទ្ធិចុះហត្ថលេខាលើកិច្ចសន្យាលទ្ធកម្មដែលមានទឹកប្រាក់ក្រោម...ដុល្លារអាមេរិក [*បញ្ចូលចំនួនទឹកប្រាក់ដែលត្រូវបានប្រគល់សិទ្ធិពីក្រសួង ស្ថាប័ន...*]
- អនុវត្តភារកិច្ចផ្សេងទៀត តាមការកំណត់ក្នុងនីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំគម្រោង និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងឯកសារគ្រប់គ្រងគម្រោង/កម្មវិធីពាក់ព័ន្ធផ្សេងទៀត។

**ប្រការ៤.**

អង្គភាពគ្រប់គ្រងគម្រោង/កម្មវិធីក្រោមក្របខណ្ឌហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍, ពីការឱ្យខ្ចីផ្ទាល់ពីរដ្ឋ, និងពីមូលបត្ររដ្ឋ បំពេញតួនាទី និងភារកិច្ច និងដំណើរការការងាររបស់ខ្លួន ដោយអនុលោមតាមនីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍។

**ប្រការ៥.**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៦.**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ នាយកវិទ្យាស្ថាន និងគ្រប់អង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន [*បញ្ចូលឈ្មោះក្រសួង ស្ថាប័ន...*] និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង** [*បញ្ចូលឈ្មោះក្រសួង...*] ឬ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង** [*បញ្ចូលឈ្មោះក្រសួង...*] ឬ

**រដ្ឋមន្ត្រីក្រសួង** [*បញ្ចូលឈ្មោះក្រសួង...*] ឬ

**ប្រធានស្ថាប័ន** [*បញ្ចូលឈ្មោះស្ថាប័ន...*]

[ហត្ថលេខានិងត្រា]

[ឈ្មោះ]

**កន្លែងទទួល ÷**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៦ [*ជាលេខប្រការចុងក្រោយបង្អស់*]
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

*(សញ្ញាក្រសួង ស្ថាប័ន)*

**ក្រសួង ស្ថាប័ន÷** *[បញ្ចូលឈ្មោះក្រសួង ស្ថាប័ន...]*

**លេខ÷** *[...]*

**ប្រកាស**

**ស្តីពី**

**ការបង្កើតគណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្ម, គណៈកម្មការវាយតម្លៃឯកសារដេញថ្លៃធំនិញ និងសំណង់ និងគណៈកម្មការវាយតម្លៃឯកសារជ្រើសរើសទីប្រឹក្សា សម្រាប់គម្រោង/កម្មវិធី** *[ បញ្ចូលឈ្មោះគម្រោង/កម្មវិធី...]* **ក្រោមក្របខណ្ឌហិរញ្ញប្បទានពី** *[ បញ្ចូលឈ្មោះស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍.../ការឱ្យខ្ចីផ្ទាល់ពីរដ្ឋ.../មូលបត្ររដ្ឋ...]*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង** *[ បញ្ចូលឈ្មោះក្រសួង...]* ឬ
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង** *[ បញ្ចូលឈ្មោះក្រសួង...]* ឬ
**រដ្ឋមន្ត្រីក្រសួង** *[ បញ្ចូលឈ្មោះក្រសួង...]* ឬ
**ប្រធានស្ថាប័ន** *[ បញ្ចូលឈ្មោះស្ថាប័ន...]*

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ *[បញ្ចូលអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន...]*
- បានឃើញអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- បានឃើញអនុក្រឹត្យលេខ ១៩២ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការកែសម្រួលមាត្រា ១ នៃអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- បានឃើញប្រកាសលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ.... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋាន... *(ក្នុងករណីបើមាន)*

- បានឃើញប្រកាសលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ.... ស្ដីពីការបង្កើតអង្គភាពគ្រប់គ្រងគម្រោង/កម្មវិធី *[...បញ្ចូលឈ្មោះគម្រោង/កម្មវិធី...]* ក្រោមក្របខណ្ឌហិរញ្ញប្បទានពី *[បញ្ចូលឈ្មោះស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍.../ការឱ្យខ្ចីផ្ទាល់ពីរដ្ឋ.../មូលបត្ររដ្ឋ...]*
- យោងតាមតម្រូវការចាំបាច់របស់ *[ បញ្ចូលឈ្មោះក្រសួង ស្ថាប័ន...]*

**សម្រេច**

**ប្រការ១._**

ត្រូវបានបង្កើតគណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្ម (Procurement Review Committee) ដែលមានសមាសភាពដូចខាងក្រោម÷

**ក. គណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្មកម្រិតធំ** (Major Procurements)

| | | | |
|---|---|---|---|
| ១. | *[ បញ្ចូលឈ្មោះ ...]* | ប្រធានភ្នាក់ងារប្រតិបត្តិគម្រោង/កម្មវិធី ឬតំណាង | ប្រធាន |
| ២. | *[ បញ្ចូលឈ្មោះ ...]* | នាយកគម្រោង/កម្មវិធី | សមាជិក |
| ៣. | *[ បញ្ចូលឈ្មោះ ...]* | តំណាងភ្នាក់ងារប្រតិបត្តិគម្រោង/កម្មវិធី | សមាជិក |
| ៤. | *[ បញ្ចូលឈ្មោះ ...]* | តំណាងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥. | *[ បញ្ចូលឈ្មោះ ...]* | តំណាងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក។ |

**ខ. គណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្មកម្រិតមធ្យម** (General Procurements)

| | | | |
|---|---|---|---|
| ១. | *[ បញ្ចូលឈ្មោះ ...]* | នាយកគម្រោង/កម្មវិធី | ប្រធាន |
| ២. | *[ បញ្ចូលឈ្មោះ ...]* | ប្រធានគ្រប់គ្រងគម្រោង/កម្មវិធី ឬតំណាង | សមាជិក |
| ៣. | *[ បញ្ចូលឈ្មោះ ...]* | តំណាងភ្នាក់ងារប្រតិបត្តិ/អនុវត្តគម្រោង | សមាជិក |
| ៤. | *[ បញ្ចូលឈ្មោះ ...]* | តំណាងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥. | *[ បញ្ចូលឈ្មោះ ...]* | តំណាងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក។ |

**គ. គណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្មកម្រិតតូច** (Minor Procurement)

| | | | |
|---|---|---|---|
| ១. | *[ បញ្ចូលឈ្មោះ ...]* | ប្រធានគ្រប់គ្រងគម្រោង/កម្មវិធី | ប្រធាន |
| ២. | *[ បញ្ចូលឈ្មោះ ...]* | មន្ត្រីទទួលបន្ទុកបច្ចេកទេស | សមាជិក |
| ៣. | *[ បញ្ចូលឈ្មោះ ...]* | តំណាងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ | សមាជិក។ |

**ប្រការ២._**

ត្រូវបានបង្កើតគណៈកម្មការវាយតម្លៃឯកសារដេញថ្លៃទិនិញ និងសំណង់ (Bid Evaluation Committee) សម្រាប់គ្រប់កម្រិត ដែលមានសមាសភាព ដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១. | *[ បញ្ចូលឈ្មោះ ...]* | មន្ត្រីទទួលបន្ទុកលទ្ធកម្ម | ប្រធាន |
| ២. | *[ បញ្ចូលឈ្មោះ ...]* | មន្ត្រីទទួលបន្ទុកបច្ចេកទេស ឬតំណាង | សមាជិក |
| ៣. | *[ បញ្ចូលឈ្មោះ ...]* | មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ | សមាជិក។ |

**ប្រការ៣.-**

ត្រូវបានបង្កើតគណៈកម្មការវាយតម្លៃឯកសារជ្រើសរើសទីប្រឹក្សា (Consultant Evaluation Committee) ដែលមានសមាសភាព ដូចខាងក្រោម៖

**ក. គណៈកម្មការវាយតម្លៃឯកសារជ្រើសរើសទីប្រឹក្សាកម្រិតធំ និងកម្រិតមធ្យម** (Major and General Procurements)

| | | | |
|---|---|---|---|
| ១. | [*បញ្ចូលឈ្មោះ ...*] | ប្រធានគ្រប់គ្រងគម្រោង/កម្មវិធី ឬតំណាង | ប្រធាន |
| ២. | [*បញ្ចូលឈ្មោះ ...*] | មន្ត្រីទទួលបន្ទុកបច្ចេកទេស ឬតំណាង | សមាជិក |
| ៣. | [*បញ្ចូលឈ្មោះ ...*] | តំណាងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤. | [*បញ្ចូលឈ្មោះ ...*] | តំណាងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក។ |

**ខ. គណៈកម្មការវាយតម្លៃឯកសារជ្រើសរើសទីប្រឹក្សាកម្រិតតូច** (Minor Procurement)

| | | | |
|---|---|---|---|
| ១. | [*បញ្ចូលឈ្មោះ ...*] | មន្ត្រីទទួលបន្ទុកបច្ចេកទេស | ប្រធាន |
| ២. | [*បញ្ចូលឈ្មោះ ...*] | មន្ត្រីទទួលបន្ទុកលទ្ធកម្ម | សមាជិក |
| ៣. | [*បញ្ចូលឈ្មោះ ...*] | តំណាងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក។ |

**ប្រការ៤.-**

គណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្ម, គណៈកម្មការវាយតម្លៃឯកសារដេញថ្លៃទំនិញ និងសំណង់, និងគណៈកម្មការវាយតម្លៃឯកសារជ្រើសរើសទីប្រឹក្សា សម្រាប់គម្រោង/កម្មវិធីក្រោមក្របខណ្ឌហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍, ពីការឱ្យខ្ចីផ្តល់ពីរដ្ឋ, និងពីមូលបត្ររដ្ឋ បំពេញតួនាទី និងភារកិច្ច និងដំណើរការការងាររបស់ខ្លួន ដោយអនុលោមតាមនីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍។

**ប្រការ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៦.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ នាយកវិទ្យាស្ថាន និងគ្រប់អង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន [*បញ្ចូលឈ្មោះក្រសួង ស្ថាប័ន...*] និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ប្រការ២ និងប្រការ៣ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង** [*បញ្ចូលឈ្មោះក្រសួង...*] ឬ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង** [*បញ្ចូលឈ្មោះក្រសួង...*] ឬ

**រដ្ឋមន្ត្រីក្រសួង** [*បញ្ចូលឈ្មោះក្រសួង...*] ឬ

**ប្រធានស្ថាប័ន** [*បញ្ចូលឈ្មោះស្ថាប័ន...*]

[ហត្ថលេខានិងត្រា]

[ឈ្មោះ]

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦ [*ជាលេខប្រការចុងក្រោយបង្អស់*]
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
លេខ...០០៤...... សហវ......

**សារាចរ**
**ស្តីពី**
**ការដាក់ឱ្យអនុវត្តប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី១**
**នៅរដ្ឋបាលស្រុក និង រដ្ឋបាលឃុំ ជំហានទី១**

យោងតាមយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥ ដែលទទួលបានការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៩, ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥, យុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៥ និង សេចក្តីជូនដំណឹងលេខ០១១ សហវ ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០២១ ស្តីពីការអនុវត្តចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំបង្កើតប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី១ ដែលមានលក្ខណៈសាមញ្ញ និង ផ្តល់ភាពងាយស្រួលក្នុងការអនុវត្តជាមួយទូរសព្ទឆ្លាតវៃតាមរយៈបណ្តាញអ៊ីនធឺណិត ។ ក្នុងទិសដៅដើម្បីជួយពន្លឿនដល់ការអនុវត្តចំណូល ចំណាយថវិការបស់រដ្ឋបាលស្រុក និង រដ្ឋបាលឃុំ ប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី១ នឹងត្រូវដាក់ឱ្យអនុវត្តសាកល្បងជំហានទី១ ជូនរដ្ឋបាលស្រុកចំនួន ៧៥ និង រដ្ឋបាលឃុំចំនួន ១៨៥ នៅក្នុងឆ្នាំ ២០២២ នេះ (ដូចមានភ្ជាប់ជូននៅក្នុងឧបសម្ព័ន្ធនៃសារាចរនេះ) ដែលមានមុខងារគ្របដណ្តប់លើប្រតិបត្តិការចំណូល ចំណាយថវិកា ដូចខាងក្រោម÷

**១.ប្រតិបត្តិការចំណូលថវិកា**

ក.បន្ទាប់ពីការបង់ចំណូលចូលគណនីចរន្តរបស់រតនាគារខេត្ត នៅធនាគារពាណិជ្ជដៃគូ រដ្ឋបាលស្រុក និង រដ្ឋបាលឃុំ ត្រូវរៀបចំសលាកបត្របង្វែរចំណូលថវិកា និង ឯកសារពាក់ព័ន្ធ ស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន រួចត្រូវស្កេនជាទម្រង់ PDF ចងក្រងជាសំណុំឯកសារតែមួយ និង ដាក់បញ្ចូលទៅក្នុងប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី១ ដើម្បីបញ្ជូនទៅរតនាគារខេត្ត ។ ចំពោះសលាកបត្រ និង ឯកសារពាក់ព័ន្ធជាច្បាប់ដើម ត្រូវរក្សាទុកនៅអង្គភាពដើមសម្រាប់ជាកម្មវត្ថុនៃការធ្វើអធិការកិច្ច ឬ សវនកម្មតាមក្រោយ ។

ខ.រតនាគារខេត្ត ដែលជាគណនេយ្យករសាធារណៈ នៅពេលទទួលបានសលាកបត្រ និង ឯកសារពាក់ព័ន្ធ តាមរយៈប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី១ ត្រូវពិនិត្យ និង ផ្ទៀងផ្ទាត់អនុលោមភាពនៃនីតិវិធីហិរញ្ញវត្ថុ ។ នៅពេលពិនិត្យឃើញថាមានអនុលោមភាពហើយ រតនាគារខេត្តត្រូវកត់ត្រា និង អនុម័តក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) រួចត្រូវអនុម័តសំណើសុំលើប្រតិបត្តិការនៅក្នុងប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី១ ជាមួយនឹងការផ្តល់ជូនជាលេខសម្គាល់ប្រតិបត្តិការផ្លូវការ ដែលទទួលបានពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ទៅរដ្ឋបាលស្រុក និង រដ្ឋបាលឃុំ តាមរយៈប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី១ វិញ ។ ក្នុងករណីពិនិត្យឃើញមានការបង់ចំណូលពីរដ្ឋបាលស្រុក និង/ឬ រដ្ឋបាលឃុំ ប៉ុន្តែមិនទាន់ទទួលបានសលាកបត្រនៅ

ក្នុងប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី១ យោងតាមប្រកាសឥណទានរបស់ធនាគារ (Credit Advice) រតនាគារខេត្តត្រូវកត់ត្រាទៅក្នុងគណនីចំណូលបណ្ដោះអាសន្នសិន នៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ។

គ. ករណីសលាកបត្រ និង ឯកសារពាក់ព័ន្ធ ពុំទាន់មានលក្ខណៈត្រឹមត្រូវ និង មិនអនុលោមតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន រតនាគារខេត្តត្រូវស្នើសុំការបញ្ជាក់បន្ថែមពីអាណាប័កនៃរដ្ឋបាលស្រុក និង រដ្ឋបាលឃុំ ឬ ផ្ដល់ឯកសារបន្ថែម ដោយបញ្ជាក់អំពីចំណុចខ្វះខាតតាមរយៈប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី១ ដើម្បីបញ្ជាក់ពីការទទួលខុសត្រូវ ។ ក្នុងករណីចាំបាច់ រតនាគារខេត្តមានសិទ្ធិស្នើសុំការបញ្ជាក់ ឬ ឯកសារច្បាប់ដើមពាក់ព័ន្ធបន្ថែម ។

ឃ. នៅពេលដែលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ត្រូវបានដាក់ឱ្យអនុវត្តដល់រដ្ឋបាលស្រុក និង/ឬ រដ្ឋបាលឃុំ ណាមួយដែលកំពុងអនុវត្តប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី១ រដ្ឋបាលស្រុក និង/ឬ រដ្ឋបាលឃុំ ទាំងនោះ នឹងត្រូវផ្លាស់ប្ដូរទៅអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) នោះវិញ ។

**២. ប្រតិបត្តិការចំណាយថវិកា**

ក. ក្រោយពីកិច្ចជម្រះបញ្ជីត្រូវបានបញ្ចប់ រដ្ឋបាលស្រុក និង រដ្ឋបាលឃុំ ត្រូវរៀបចំបោះផ្សាយអាណត្តិបើកប្រាក់សម្រាប់ទូទាត់រាល់ការចំណាយថវិកាទាំងអស់ ដោយភ្ជាប់ជាមួយលិខិតយុត្តិការចំណាយស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន រួចត្រូវស្កេនជាទម្រង់ PDF ចងក្រងជាសំណុំឯកសារតែមួយ និង ដាក់បញ្ចូលទៅក្នុងប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី១ ដើម្បីបញ្ជូនទៅរតនាគារខេត្ត ។ រីឯ អាណត្តិបើកប្រាក់ និង លិខិតយុត្តិការចំណាយជាច្បាប់ដើម ត្រូវរក្សាទុកនៅអង្គភាពដើមសម្រាប់ជាកម្មវត្ថុនៃការធ្វើអធិការកិច្ច ឬ សវនកម្មតាមក្រោយ ។

ខ. រតនាគារខេត្ត ដែលជាគណនេយ្យករសាធារណៈ នៅពេលទទួលបានអាណត្តិបើកប្រាក់ និង លិខិតយុត្តិការចំណាយ តាមរយៈប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី១ ត្រូវពិនិត្យនិងផ្ទៀងផ្ទាត់អនុលោមភាពនៃនីតិវិធីហិរញ្ញវត្ថុ ។ នៅពេលពិនិត្យឃើញថាមានអនុលោមភាពហើយ រតនាគារខេត្តត្រូវកត់ត្រា និង អនុម័តក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) រួចត្រូវអនុម័តសំណើសុំលើប្រតិបត្តិការនៅក្នុងប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី១ ជាមួយនឹងការផ្ដល់ជូនជាលេខសម្គាល់ប្រតិបត្តិការផ្លូវការ ដែលទទួលបានពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ទៅរដ្ឋបាលស្រុក និង រដ្ឋបាលឃុំ តាមរយៈប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី១ វិញ មុនពេលបើកផ្ដល់សាច់ប្រាក់ទៅតាមអាណត្តិបើកប្រាក់ ។

គ. ករណីអាណត្តិបើកប្រាក់ និង លិខិតយុត្តិការចំណាយ ពុំទាន់មានលក្ខណៈត្រឹមត្រូវ និង មិនអនុលោមតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន រតនាគារខេត្ត ត្រូវស្នើសុំការបញ្ជាក់បន្ថែមពីអាណាប័កនៃរដ្ឋបាលស្រុក និង រដ្ឋបាលឃុំ ឬ ផ្ដល់ឯកសារបន្ថែម ឬ មិនធ្វើការទូទាត់ជូន ដោយបញ្ជាក់អំពីចំណុចខ្វះខាតតាមរយៈប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី១ ដើម្បីបញ្ជាក់ពីការទទួលខុសត្រូវ ។ ក្នុងករណីចាំបាច់ រតនាគារខេត្ត មានសិទ្ធិស្នើសុំការបញ្ជាក់ ឬ ឯកសារច្បាប់ដើមពាក់ព័ន្ធបន្ថែម ។

ឃ. នៅពេលដែលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ត្រូវបានដាក់ឱ្យអនុវត្តដល់រដ្ឋបាលស្រុក និង/ឬ រដ្ឋបាលឃុំ ណាមួយដែលកំពុងអនុវត្តប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី១ រដ្ឋបាលស្រុក និង/ឬ រដ្ឋបាលឃុំ ទាំងនោះ នឹងត្រូវផ្លាស់ប្តូរទៅអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) នោះវិញ ។

ទទួលបានសារាចរនេះ អភិបាលនៃគណៈអភិបាលខេត្ត អភិបាលនៃគណៈអភិបាលស្រុក មេឃុំ លោក លោកស្រីប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ប្រធានរតនាគារខេត្ត និង នាយកទីចាត់ការហិរញ្ញវត្ថុសាលាខេត្ត ដែលជាក្រុមការងារគាំទ្រការរៀបចំ និង អនុវត្តថវិការបស់រដ្ឋបាលស្រុក មេត្តាជ្រាប និង សម្របសម្រួលដល់កិច្ចដំណើរការអនុវត្តប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី១ ដល់រដ្ឋបាលស្រុក និង រដ្ឋបាលឃុំ ដូចមានចែងនៅក្នុងសារាចរនេះ ឱ្យមានប្រសិទ្ធភាព និង ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ចាប់ពីថ្ងៃចេញសារាចរនេះតទៅ ។

ថ្ងៃ ចន្ទ ៩ កើត ខែ ពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៩ ខែឧសភា ឆ្នាំ ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
- អគ្គនាយកដ្ឋានរតនាគារជាតិ
- គ្រប់រដ្ឋបាលខេត្ត
- គ្រប់រដ្ឋបាលស្រុក
- គ្រប់រដ្ឋបាលឃុំ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត
- រតនាគារខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

*ឧបសម្ព័ន្ធនៃសារាចរលេខ........................ចុះថ្ងៃទី....................................*

*ស្តីពី ការដាក់ឱ្យអនុវត្តប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី១*

*នៅរដ្ឋបាលស្រុក និង រដ្ឋបាលឃុំ ជំហានទី១*

**ឈ្មោះរដ្ឋបាលស្រុកចំនួន ៧៥ និង រដ្ឋបាលឃុំចំនួន ១៨៥**

**ដែលត្រូវអនុវត្តប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី១**

**រដ្ឋបាលស្រុក ៣ និង រដ្ឋបាលឃុំ ៩ ក្នុងខេត្តបន្ទាយមានជ័យ**

១-ស្រុកម៉ាឡៃ (ឃុំបឹងបេង, ឃុំអូរសំព័រ, ឃុំអូរស្រឡៅ),

២-ស្រុកបង្គលប្ញរី (ឃុំបត់ត្រង់, ឃុំភ្នំតូច, ឃុំសំបួរ),

៣-ស្រុកព្រះនេត្រព្រះ (ឃុំព្រះនេត្រព្រះ, ឃុំបុស្សរេី, ឃុំទឹកជោរ)

**រដ្ឋបាលស្រុក ៥ និង រដ្ឋបាលឃុំ ១០ ក្នុងខេត្តបាត់ដំបង**

១-ស្រុកបាណន់ (ឃុំតាគ្រាម, ឃុំភ្នំសំពៅ),

២-ស្រុកមោងឬស្សី (ឃុំរបស់មង្គល, ឃុំតាលាស់),

៣-ស្រុកសំពៅលូន (ឃុំតាស្ដា, ឃុំសំពៅលូន),

៤-ស្រុកសំឡូត (ឃុំតាតោក, ឃុំកំពង់ល្ពៅ),

៥-ស្រុកកំរៀង (ឃុំកំរៀង, ឃុំបឹងរាំង)

**រដ្ឋបាលស្រុក ២ និង រដ្ឋបាលឃុំ ៣ ក្នុងខេត្តកំពង់ចាម**

១-ស្រុកកងមាស (ឃុំព្រែកក្របៅ, ឃុំអង្គរបាន),

២-ស្រុកបាយ (ឃុំសំបូរ)

**រដ្ឋបាលស្រុក ២ និង រដ្ឋបាលឃុំ ៤ ក្នុងខេត្តកំពង់ឆ្នាំង**

១-ស្រុកបរិបូណ៌ (ឃុំពន្លៃ, ឃុំពេជចង្វារ),

២-ស្រុករលាប្អៀរ (ឃុំជើងគ្រាវ, ឃុំអណ្ដូងស្នាយ)

**រដ្ឋបាលស្រុក ២ និង រដ្ឋបាលឃុំ ៧ ក្នុងខេត្តកំពង់ស្ពឺ**

១-ស្រុកសំរោងទង (ឃុំកាហែង, ឃុំត្រពាំងគង, ឃុំរលាំងចក, ឃុំសែនឌី),

២-ស្រុកឧដុង្គ (ឃុំភ្នំតូច, ឃុំយុទ្ធសាមគ្គី, ឃុំក្សេមក្សាន្ត)

**រដ្ឋបាលស្រុក ២ និង រដ្ឋបាលឃុំ ៤ ក្នុងខេត្តកំពង់ធំ**

១-ស្រុកសន្ទុក (ឃុំជ្រាប់, ឃុំកកោះ),

២-ស្រុកតាំងគោក (ឃុំច្រនាង, ឃុំសូយោង)

**រដ្ឋបាលស្រុក ៣ និង រដ្ឋបាលឃុំ ៣ ក្នុងខេត្តកំពត**

១-ស្រុកឈូក (ឃុំបឹងនិមល),

២-ស្រុកបន្ទាយមាស (ឃុំព្រៃថ្នង),

៣-ស្រុកទឹកឈូ (ឃុំព្រៃឃ្មុំ)

**រដ្ឋបាលស្រុក ៥ និង រដ្ឋបាលឃុំ ១៤ ក្នុងខេត្តកណ្តាល**

១-ស្រុកកណ្តាលស្ទឹង (ឃុំគោកទ្រព្យ, ឃុំព្រែកស្លែង),

២-ស្រុកខ្សាច់កណ្តាល (ឃុំស៊ីធរ, ឃុំវិហារសួគ៌, ឃុំសន្លុង, ឃុំពុកឬស្សី, ឃុំព្រែកអំពិល, ឃុំព្រះប្រសប់),

៣-ស្រុកល្វាឯម (ឃុំសំបួរ, ឃុំអរិយក្សត្រ),

៤-ស្រុកកោះធំ (ឃុំកោះធំ, កោះធំខ),

៥-ស្រុកលើកដែក (ឃុំសណ្តរ, ឃុំកំពង់ភ្នំ)

**រដ្ឋបាលស្រុក ៣ និង រដ្ឋបាលឃុំ ១៣ ក្នុងខេត្តកោះកុង**

១-ស្រុកស្រែអំបិល (ឃុំបឹងព្រាវ, ឃុំជីខលើ, ឃុំជីខក្រោម, ឃុំជ្រោយស្វាយ, ឃុំដងពែង, ឃុំស្រែអំបិល),

២-ស្រុកគិរីសាគរ (ឃុំកោះស្តេច, ឃុំភ្ញីមាស, ឃុំព្រែកខ្សាច់),

៣-ស្រុកបុទុមសាគរ (ឃុំអណ្តូងទឹក, ឃុំកណ្តោល, ឃុំតានូន, ឃុំថ្មស)

**រដ្ឋបាលស្រុក ៥ និង រដ្ឋបាលឃុំ ១៣ ក្នុងខេត្តក្រចេះ**

១-ស្រុកឆ្លូង (ឃុំពង្រ, ឃុំខ្សាច់អណ្តែត, ឃុំព្រែកសាម៉ាន់),

២-ស្រុកព្រែកប្រសព្វ (ឃុំកោះតាស៊ុយ, ឃុំកំពង់គរ, ឃុំចំបក់),

៣-ស្រុកសំបូរ (ឃុំក្បាលដំរី, ឃុំសណ្តាន់),

៤-ស្រុកស្នួល (ឃុំឃ្សឹម,ឃុំស្នួល ),

៥-ស្រុកចិត្របុរី (ឃុំកន្ទួត, ឃុំសំបុក, ឃុំថ្មគ្រែ)

**រដ្ឋបាលស្រុក ២ និង រដ្ឋបាលឃុំ ៤ ក្នុងខេត្តមណ្ឌលគិរី**

១-ស្រុកកោះញែក (ឃុំសុខសាន្ត, ឃុំអបួនលើ ),

២-ស្រុកពេជ្រាដា (ឃុំប៊ូស្រា, ឃុំស្រែអំពូម)

**រដ្ឋបាលស្រុក ៣ និង រដ្ឋបាលឃុំ ៦ ក្នុងខេត្តព្រះវិហារ**

១-ស្រុករវៀង (ឃុំរក្សា, ឃុំរម្មទី),

២-ស្រុកជ័យសែន (ឃុំតស៊ូ, ឃុំពុទ្រា),

៣-ស្រុកជាំក្សាន្ត (ឃុំជាំក្សាន្ត, ឃុំយាង)

**រដ្ឋបាលស្រុក ១១ និង រដ្ឋបាលឃុំ ២០ ក្នុងខេត្តព្រៃវែង**

១-ស្រុកបាភ្នំ (ឃុំឈើកាច់),

២-ស្រុកកំចាយមារ (ឃុំស្មោងខាងជើង, ឃុំត្របែក),

៣-ស្រុកកំពង់ត្របែក (ឃុំគោខ្ចក, ឃុំកំពង់ត្របែក),

៤-ស្រុកកញ្ជ្រៀច (ឃុំឆ្គោត, ឃុំចុងអំពិល),

៥-ស្រុកមេសាង (ឃុំត្រពាំងស្រែ, ឃុំច្រេស),

៦-ស្រុកពាមជរ (ឃុំកំពង់ប្រាសាទ, ឃុំកោះរកា, ឃុំកោះសំពៅ, ឃុំព្រែកក្របៅ),

៧-ស្រុកពារាំង (ឃុំរាប),

៨-ស្រុកព្រះស្តេច (ឃុំបឹងដោល, ឃុំរំចេក),

៩-ស្រុកពោធិ៍រៀង (ឃុំព្រែកអន្ទះ),

១០-ស្រុកស៊ីធរកណ្តាល (ឃុំរំលេច),

១១-ស្រុកស្វាយអន្ទរ (ឃុំជ្រៃ, ឃុំដំរីពួន)

**រដ្ឋបាលស្រុក ៣ និង រដ្ឋបាលឃុំ ៩ ក្នុងខេត្តពោធិ៍សាត់**

១-ស្រុកកណ្ដៀង (ឃុំកណ្ដៀង, ឃុំស្វាយលួង, ឃុំរាំងទិល),

២-ស្រុកបាកាន (ឃុំអូរតាប៉ោង, ឃុំបឹងខ្នារ, ឃុំត្រពាំងជង),

៣-ស្រុកវាលវែង (ឃុំក្រពើពីរ, ឃុំប្រម៉ោយ, ឃុំអូរសោម)

**រដ្ឋបាលស្រុក ២ និង រដ្ឋបាលឃុំ ៤ ក្នុងខេត្តរតនគិរី**

១-ស្រុកអូរជុំ (ឃុំកាឡៃ, ឃុំសាមគ្គី),

២-ស្រុកអូរយ៉ាដាវ (ឃុំសេសាន, ឃុំប៉ក់ញ៉ៃ)

**រដ្ឋបាលស្រុក ៣ និង រដ្ឋបាលឃុំ ៩ ក្នុងខេត្តសៀមរាប**

១-ស្រុកសូទ្រនិគម (ឃុំកំពង់ឃ្លាំង, ឃុំដានរុន, ឃុំសំរោង),

២-ស្រុកបន្ទាយស្រី (ឃុំខ្នារសណ្ដាយ, ឃុំឃុនរាម, ឃុំរុនតាឯក),

៣-ស្រុកអង្គរជុំ (ឃុំចារឈូក, ឃុំស្រែខ្វាវ, ឃុំគោល)

**រដ្ឋបាលស្រុក ១ និង រដ្ឋបាលឃុំ ៣ ក្នុងខេត្តព្រះសីហនុ**

១-ស្រុកព្រៃនប់ (ឃុំបឹងតាព្រហ្ម, ឃុំទឹកល្អក់, ឃុំអណ្ដូងថ្ម)

**រដ្ឋបាលស្រុក ៣ និង រដ្ឋបាលឃុំ ៥ ក្នុងខេត្តស្ទឹងត្រែង**

១-ស្រុកសេសាន (ឃុំកំភុន, ឃុំស្រែគរ),

២-ស្រុកបុរីអូរស្វាយសែនជ័យ (ឃុំអូរស្វាយ, ឃុំកោះស្នែង),

៣-សៀមប៉ាង (ឃុំថ្មកែវ)

**រដ្ឋបាលស្រុក ៣ និង រដ្ឋបាលឃុំ ៧ ក្នុងខេត្តស្វាយរៀង**

១-ស្រុកស្វាយជ្រំ (ឃុំដូនស, ឃុំស្វាយធំ, ឃុំក្រោលគោ),

២-ស្រុកស្វាយទាប (ឃុំរមាំងថ្កោល),

៣-ស្រុករមាសហែក (ឃុំសំបួរ),

៤-ឃុំកំពង់អំពិល និង ឃុំពងទឹក នៃស្រុករំដួល

**រដ្ឋបាលស្រុក ៣ និង រដ្ឋបាលឃុំ ១៣ ក្នុងខេត្តតាកែវ**

១-ស្រុកគីរីវង់ (ឃុំកំណប់, ឃុំកំពែង, ឃុំព្រៃអំពក, ឃុំសោម, ឃុំតាអូរ),

២-ស្រុកទ្រាំង (ឃុំអង្កាញ់, ឃុំអង្គខ្នុរ, ឃុំខ្វាវ, ឃុំព្រៃស្លឹក, ឃុំឆ្លក),

៣-ស្រុកត្រាំកក់ (ឃុំស្រែរនោង, ឃុំញ៉ែងញ៉ង, ឃុំគូស)

**រដ្ឋបាលស្រុក ៤ និង រដ្ឋបាលឃុំ ១៩ ក្នុងខេត្តឧត្តរមានជ័យ**

១-ស្រុកអន្លង់វែង (ឃុំអន្លង់វែង, ឃុំត្រពាំងប្រីយ៍, ឃុំត្រពាំងតាវ, ឃុំថ្លាត, ឃុំលំទង),

២-ស្រុកបន្ទាយអំពិល (ឃុំអំពិល, ឃុំបេង, ឃុំគោកខ្ពស់, ឃុំគោកមន),

៣-ស្រុកចុងកាល់ (ឃុំជើងទៀន, ឃុំចុងកាល់, ឃុំក្រសាំង, ឃុំពង្រ),

៤-ស្រុកត្រពាំងប្រាសាទ (ឃុំបាក់អន្លូង, ឃុំផ្អាវ, ឃុំអូរស្វាយ, ឃុំព្រះប្រឡាយ, ឃុំទំនប់ដាច់, ឃុំត្រពាំងប្រាសាទ)

**រដ្ឋបាលស្រុក ១ និង រដ្ឋបាលឃុំ ១ ក្នុងខេត្តកែប**

១-ស្រុកដំណាក់ចង្អើរ (ឃុំពងទឹក)

**រដ្ឋបាលស្រុក ១ និង រដ្ឋបាលឃុំ ២ ក្នុងខេត្តប៉ៃលិន**

១-ស្រុកសាលាក្រៅ (ឃុំស្ទឹងកាច់, ឃុំអូរអណ្តូង)

**រដ្ឋបាលស្រុក ៣ និង រដ្ឋបាលឃុំ ៣ ក្នុងខេត្តត្បូងឃ្មុំ**

១-ស្រុកពញាក្រែក (ឃុំកោងកាង),

២-ស្រុកមេមត់ (ឃុំជាំ),

៣-ស្រុកត្បូងឃ្មុំ (ឃុំស្រឡប់)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខៈ ៧៨៤ ឧ.វ.ប.ន./ក.ក./ប្រ.ក

ថ្ងៃ............... ខែ............... ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...១៤... ខែ...កក្កដា... ឆ្នាំ២០២២

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ០៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងក្រុងតាខ្មៅ ជាមួយស្រុកស្អាង និងស្រុកកណ្តាលស្ទឹង នៃខេត្តកណ្តាល
- យោងលិខិតលេខ២៣៤/១៤ គ.វ.ក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៤ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រកាត់ដេរ និងចាក់សម្លៀកបំពាក់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២ របស់ក្រុមហ៊ុន ហ្គោលឌិន ស្តារ ខបភើរេត ឌីវេឡុបមេន (ខេមបូឌា) លីមីធីត

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន **ហ្គោលឌិន ស្តារ ខបភើរេត ឌីវេឡុបមេន (ខេមបូឌា) លីមីធីត (GOLDEN STAR CORPORATE DEVELOPMENT (CAMBODIA) LIMITED.)** តំណាងដោយលោកស្រី **DU, XUNMEI** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ **EC2550171** ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ បង្កើតរោងចក្រ**កាត់ដេរ និងចាក់សម្លៀកបំពាក់** ដែលមានទីតាំងស្ថិតនៅ**សួនឧស្សាហកម្ម ស៊ូចូ (ខេមបូឌា) ភូមិព្រែកសំរោង សង្កាត់កោះខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្តាល**។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
|---|---|
| **១-សម្លៀកបំពាក់ (កាត់ដេរ)** | **១៤១០** |
| **២-សម្លៀកបំពាក់ (ចាក់)** | **១៤៣០** |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រកាត់ដេរ និងចាក់សម្លៀកបំពាក់ ហ្គោលឌិន ស្តារ ឧបករេត ឌីវេឡុបមេន (ខេមបូឌា) លីមីធីត** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ដាច់ចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ២៥៨ ឧស.កឧ.ប្រក.០៥ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងលិខិតលេខ៤២៣១ ឧវបន.កឧ.លស. ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការប្តូរអភិបាល របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
**រដ្ឋលេខាធិការ**

**មាន សុភា**

**ចម្លងជូន៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងបរិស្ថាន
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -រាជកិច្ច
- -វិទ្យាស្ថានស្តង់ដារកម្ពុជា
- -មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- -សាលាខេត្តកណ្តាល
- -មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកណ្តាល
- -រដ្ឋបាលក្រុងតាខ្មៅ
- -រដ្ឋបាលឃុំរកាខ្ពស់

"ដើម្បីជូនជ្រាប"
- -ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: [illegible] ថ្ងៃ[illegible] ខែ[illegible] ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...១៥... ខែ...កក្កដា... ឆ្នាំ២០២២

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
